# សេចក្តីប្រកាសព័ត៌មាន
## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៣

អ្នកនាំពាក្យ នៃក្រសួងការបរទេសជប៉ុន បានចេញសេចក្តីថ្លែងការមួយស្តីពីការចាប់ផ្តើមរាជរដ្ឋាភិបាលថ្មីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម ៖

១. ក្រោយពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលបានប្រព្រឹត្តទៅនៅក្នុងខែកក្កដា នៅព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលថ្មីដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ត្រូវបានបង្កើតឡើងកាលពីថ្ងៃទី ២៤ ខែកញ្ញា ។

២. ប្រទេសជប៉ុនបាន និងកំពុងគាំទ្រយ៉ាងកសម្ម ដល់កិច្ចខិតខំប្រឹងប្រែងកសាងប្រទេសជាតិរបស់កម្ពុជារហូតមកទល់នឹងពេលបច្ចុប្បន្ន ។ ប្រទេសជប៉ុនមានសេចក្តីសង្ឃឹមថា នឹងបានឃើញកិច្ចពិភាក្សា និងកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធនានាមានដំណើរការទៅមុខ ដើម្បីឱ្យរាជរដ្ឋាភិបាលថ្មី និងរដ្ឋសភាថ្មីអាចដំណើរការប្រកបដោយភាពរលូន ហើយវិធានការផ្សេងៗអាចត្រូវបានអនុវត្តយ៉ាងប្រាកដប្រជា ឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសកម្ពុជា ។

(ចប់)

* អត្ថបទខាងលើ គឺជាអត្ថបទបកប្រែបណ្តោះអាសន្ន ។ កាលបរិច្ឆេទខាងលើ គឺជាកាលបរិច្ឆេទ នៃការចេញសេចក្តីប្រកាសព័ត៌មានដើមជាភាសាជប៉ុន ។